ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ ៥៨

ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១

**សាលដីកា**

លេខ ៤០១ IV

ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១

# សាលដីកា

## នាមប្រជាពលរដ្ឋខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម៖

១.លោកជំទាវ [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២.ឯកឧត្តម [redacted] ចៅក្រម

៣.ឯកឧត្តម [redacted] ចៅក្រម

៤.ឯកឧត្តម [redacted] ចៅក្រម

៥.ឯកឧត្តម [redacted] ចៅក្រម

**ចៅក្រមរបាយការណ៍**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្ដឹងសាទុក្ខលេខ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] គីមហេង ដែលធ្វើឡើងតាមរយៈលោក [redacted] ទ្រី និងលោក [redacted] ចតនា ជាមេធាវីតំណាងក្នុងការប្ដឹងសាទុក្ខ,បណ្ដឹងសាទុក្ខលេខ ៤៨ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីនី និងបណ្ដឹងសាទុក្ខលេខ ៤៩ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] អេនឌី ប្ដឹងសាទុក្ខចំពោះសាលដីកាលេខ ០១ ក្រVI.ភ.ស ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

**បុគ្គលប្ដឹងសាទុក្ខ៖**

១.ជនជាប់ចោទឈ្មោះ [redacted] អេនឌី ភេទប្រុស អាយុ ៥១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ មានទីកន្លែងកំណើតនៅសង្កាត់លេខ១ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួនផ្ទះ



Scanned with CamScanner

[redacted]ង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted] (ស) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ជាទីតិជន ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ PJ ចំនួន ០១ ខែ ។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៧៧ ត.ព្រ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១១។

មេធាវីការពារសិទ្ធិលោកស្រី [redacted] **សុវ៉ាន**

**ជាប់ចោទពីបទ** ការផលិតគ្រឿងញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ, ជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់, រក្សាទុកអាវុធហាមឃាត់ខុសច្បាប់ និងការមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីផ្ដន្ទាទោសបទមជ្ឈិម ប្រព្រឹត្តនៅចំណុចដីឡូតិ៍គ្មានលេខ ក្រុម១៤ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣២.១ថ្មី, ៣៣ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ២០ នៃច្បាប់ស្ដីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ, មាត្រា ៨៧ និងមាត្រា ៩០ នៃក្រមព្រហ្មទណ្ឌ។

២-ជនជាប់ចោទឈ្មោះ [redacted] **ស្រីនី** ភេទស្រី អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជួយលក់ដូរមីង មានទីកន្លែងកំណើតនៅភូមិស្វាយតានី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល ទីលំនៅមុនពេលឃុំ[redacted]សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] (រ) ម្ដាយឈ្មោះ[redacted] (រ) នៅលីវ ជាទីតិជន ទោសពីមុនគ្មាន។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៧៨ ត.ព្រចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១១។

មេធាវីការពារសិទ្ធិលោកស្រី [redacted] **សុវ៉ាន**

**ជាប់ចោទពីបទ** ការផលិតគ្រឿងញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ និងជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅចំណុចដីឡូតិ៍គ្មានលេខ ក្រុម១៤ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣២.១ថ្មី, ៣៣ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ជនជាប់ចោទឈ្មោះ[redacted] **ឆមហេង** ភេទប្រុស អាយុ ៤២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងថតរូប មានទីកន្លែងកំណើតនៅសង្កាត់ចាក់អង្រែក្រោម រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួនផ្ទះលេខ៩៥១៣ ក្រុម២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាទីតិជន ទោសពីមុនគ្មាន។



Scanned with CamScanner

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩៦៤ ត.ព្រ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១។

មេធាវីការពារសិទ្ធិលោក [redacted] ទ្រី, លោ[redacted]ខេង, លោក [redacted]គឹមហ៊ត់ និងលោក[redacted]ចតនា

**ជាប់ចោទពីបទ** សមគំនិតក្នុងអំពើផលិតគ្រឿងញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ និងសមគំនិតជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅចំណុចដីឡូតិ៍គ្មានលេខ ក្រុម ១៤ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤៣, មាត្រា ៣២.១ថ្មី, ៣៣ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។

**បុគ្គលដែលមានសកម្មភាពជាប់ពាក់ព័ន្ធ**

៤-ជនជាប់ចោទឈ្មោះ[redacted] **ដារិទ្ធ** ភេទប្រុស អាយុ ៣៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកពេទ្យ មានទីកន្លែងកំណើតនៅភូមិស្រែអន្ទក់ ឃុំអំពិលប្រាំដើម ស្រុកបវេល ខេត្តបាត់ដំបង ទីលំនៅមុនពេល[redacted] ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] សុវណ្ណ "រ" ម្ដាយឈ្មោ[redacted] គន្ធា "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩៦២ ត.ព្រ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១១។

**ជាប់ចោទពីបទ**រក្សាទុកនូវសារធាតុសម្រាប់ផ្សំគ្រឿងញៀនក្នុងគោលដៅយកទៅផលិតគ្រឿងញៀន ប្រព្រឹត្តនៅចំណុចពេទ្យមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា-ជប៉ុនបឹងត្របែក សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីដើមឆ្នាំ២០១១ និងបទបំបាត់វត្ថុតាង-បំផ្លាញចោលសារធាតុសម្រាប់ផ្សំផលិតគ្រឿងញៀន ប្រព្រឹត្តនៅចំណុចពេទ្យមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា-ជប៉ុនបឹងត្របែក សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៨.១ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៥៣៣ នៃក្រមព្រហ្មទណ្ឌ។

៥-ជនជាប់ចោទឈ្មោះ[redacted] **សុខណ្ណា** ភេទប្រុស អាយុ ៦២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមន្ត្រីចូលនិវត្តន៍ មានទីកន្លែងកំណើតនៅភូមិចាក់អង្រែក្រោម ឃុំចាក់អង្រែ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ទីលំនៅបច្ចុ[redacted]ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] "ស" ម្ដាយឈ្មោះ[redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ជានីតិជន ទោសពីមុនគ្មាន។



Scanned with CamScanner

នៅក្រៅឃុំតាមដីកាសម្រេចលេខ ៨១៦ ត.ព្រ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១១។

**ជាប់ចោទពីបទ** សមគំនិតបំបាត់វត្ថុតាង-បំផ្លាញចោលសារធាតុសម្រាប់ផ្សំផលិតគ្រឿងញៀន ប្រព្រឹត្តនៅចំណុចរោងពុម្ពមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា-ជប៉ុនបឹងត្របែក សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៥៣៣ នៃក្រមព្រហ្មទណ្ឌ។

៦-ជនជាប់ចោទឈ្មោះ [redacted] **ចាច** ភេទប្រុស អាយុ ៤៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបើកបររថយន្ត មានទីកន្លែងកំណើតនៅភូមិចុងកោះគរ ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ទីលំនៅមុន[redacted]ស្រុកស្អាង ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ជានីតិជន ទោសពីមុនគ្មាន។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៦៣ ត.ព្រ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១។

**ជាប់ចោទពីបទ** សមគំនិតក្នុងអំពើផលិតគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រព្រឹត្តនៅចំណុចដីឡូតិ៍គ្មានលេខ ក្រុម ១៤ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ និងបទ បំបាត់វត្ថុតាង-បំផ្លាញចោលសារធាតុសម្រាប់ផ្សំផលិតគ្រឿងញៀន ប្រព្រឹត្តនៅចំណុចរោងពុម្ពមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា-ជប៉ុនបឹងត្របែក សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៣, មាត្រា ៣២.១ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ២៩ និងមាត្រា ៥៣៣ នៃក្រមព្រហ្មទណ្ឌ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង ២៣:៣០នាទី ការិយាល័យប្រឆាំងគ្រឿងញៀនបានចុះបង្ក្រាបជាក់ស្តែង និងឆែកឆេរទីតាំងផលិតគ្រឿងញៀនខុសច្បាប់ ហើយឃាត់ខ្លួនឈ្មោះ [redacted] អេនឌី, ឈ្មោះ [redacted] ស្រីនី និងឈ្មោះ ណៃ វ៉ាន់ណេត ព្រមទាំងដកហូតវត្ថុតាង និងឧបករណ៍ដែលពាក់ព័ន្ធនឹងបទល្មើសមួយចំនួនធំ។ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ សមត្ថកិច្ចបាន ធ្វើការស្រាវជ្រាវ និងបន្តធ្វើការឆែកឆេរផ្ទះលេខ៥ បូរីពិភពថ្មី សង្កាត់ចោមចៅ ខណ្ឌដង្កោ ដកហូតបានវត្ថុតាងសារធាតុផ្សំផលិតគ្រឿងញៀនចំនួន ១៤៥ គ្រេស, ម៉ូទ័រចំនួន ០៨ គ្រឿង, ជីឡាវចំនួន ០៨កែវ, ធុងទឹកកកជ័រពណ៌ក្រហមចំនួន ១៥ធុង, ចានដែកចំនួន ១២,



Scanned with CamScanner

ជញ្ជីងថ្លឹងគ្រឿងញៀនចំនួន ០១គ្រឿង និងពុងដែកចំនួន ០២ ។ នៅដើមឆ្នាំ២០១១ ឈ្មោះ [redacted] អេនឌី បានយកសារធាតុគីមីចំនួនប្រហែលជា ៣០កេស ទៅផ្ញើទុកនៅពេងពុម្ពជម្ប មណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា-ជប៉ុន បឹងត្របែក ដោយមានឈ្មោះ [redacted] ដារិទ្ធ ជាក្មួយថ្លៃជាអ្នករក្សាទុក។ ក្នុងអំឡុងពេលរក្សាទុកឈ្មោះ [redacted]ថាច បានយករថយន្តរបស់ពេងពុម្ពដឹកជាតុគីមីបន្ទំនឹងគ្រឿងសំណង់ទៅផ្តល់ឱ្យឈ្មោះ [redacted]អេនឌី ចំណែកឈ្មោះ[redacted]គីមហេង បានជួយក្នុងការយាមការពារ និងមើលខុសត្រូវទីតាំងផលិតគ្រឿងញៀន និងជួញដូរគ្រឿងញៀនរបស់ឈ្មោះ [redacted] អេនឌី ។ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ឈ្មោះ [redacted]ដារិទ្ធ បានដឹងថាឈ្មោះ [redacted] អេនឌី ជាអ្នកផលិតគ្រឿងញៀន និងខ្លួនមានពាក់ព័ន្ធនឹងការរក្សាទុកសារជាតុគីមីរបស់ឈ្មោះ [redacted]អេនឌី នោះក៏បានពិគ្រោះយោបល់ជាមួយឈ្មោះ [redacted] សុវណ្ណ ជាឪពុករកវិធីដោះស្រាយ រហូតដល់ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ ឈ្មោះ[redacted]ដារិទ្ធ, ឈ្មោះ [redacted]ថាច, ឈ្មោះ[redacted] កុសល និងឈ្មោះ [redacted] ជា បានកំទេចចោលសារជាតុគីមីទាំងអស់ដែលនៅសល់ ដោយមានការចូលរួមបញ្ជារបស់ឈ្មោះ គីម សុវណ្ណ ផង។

**-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៧៨ ក.ប.៤ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖**

១.ឱ្យឈ្មោះ [redacted] ថាច ភេទប្រុស អាយុ ៤៩ ឆ្នាំ ជាតិខ្មែរ រួចខ្លួនពីបទសមគំនិតក្នុងអំពើផលិតគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រព្រឹត្តនៅចំណុចដីឡូត៍គ្មានលេខ ក្រុម១៤ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.ផ្តន្ទាទោសជនជាប់ចោទ ៖

ក.ឈ្មោះ[redacted] អេនឌី ភេទប្រុស អាយុ ៥១ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារអស់មួយជីវិត និងពិន័យជាប្រាក់ ៥០.០០០.០០០៛ (ហាសិបលានរៀល)

ពីបទ ការផលិតគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ, ជួញដូរគ្រឿងញៀមហាមឃាត់ខុសច្បាប់, រក្សាទុកអាវុធហាមឃាត់ខុសច្បាប់ និង ការមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម ប្រព្រឹត្តនៅចំណុចដីឡូត៍គ្មានលេខ ក្រុម១៤ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ តាមមាត្រា ៣២.១ ថ្មី, ៣៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យ



Scanned with CamScanner

គ្រឿងញៀន, មាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ និងមាត្រា ៨៧.៩០ នៃក្រមព្រហ្មទណ្ឌ។

ខ.ឈ្មោះ [redacted] ស្រីនី ភេទស្រី អាយុ ១៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ២០ឆ្នាំ (ម្ភៃឆ្នាំ) និងពិន័យជាប្រាក់ ៤០.០០០.០០០៛ (សែសិបលានរៀល)

ពីបទ ការផលិតគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ និងជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅចំណុចដីឡូតិ៍គ្មានលេខ ក្រុម១៤ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១១ តាមមាត្រា ៣២.១ ថ្មី និង ៣៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

គ.ឈ្មោះ [redacted] ដារិទ្ធ ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤ឆ្នាំ (បួនឆ្នាំ) តែទោសពីនេះអនុវត្តក្នុងពន្ធនាគាររយៈពេល ០២ឆ្នាំ (ពីរឆ្នាំ) ទោសដែលនៅសល់ត្រូវព្យួរ

ពីបទ រក្សាទុកនូវសារធាតុសម្រាប់ផ្សំគ្រឿងញៀនក្នុងគោលដៅយកទៅផលិតគ្រឿងញៀន ប្រព្រឹត្តនៅចំណុចរោងពុម្ពមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា-ជប៉ុនបឹងត្របែក សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីដើមឆ្នាំ២០១១ និងបទ បំបាត់វត្ថុតាង-បំផ្លាញចោលសារធាតុសម្រាប់ផ្សំផលិតគ្រឿងញៀន ប្រព្រឹត្តនៅចំណុចរោងពុម្ពមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា-ជប៉ុនបឹងត្របែក សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ តាមមាត្រា ៣៨.១ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៥៣៣, ១០៨នៃក្រមព្រហ្មទណ្ឌ។

ឃ.ឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ ៦២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ២០ឆ្នាំ (ពីរឆ្នាំ) តែទោសនេះត្រូវព្យួរ

ពីបទ សមគំនិតបំបាត់វត្ថុតាង-បំផ្លាញចោលសារធាតុសម្រាប់ផ្សំផលិតគ្រឿងញៀន ប្រព្រឹត្តនៅចំណុចរោងពុម្ពមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា-ជប៉ុនបឹងត្របែក សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា ២៩, ៥៣៣ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

ង.ឈ្មោះ [redacted] ហាច ភេទប្រុស អាយុ ៤៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ១៨ ខែ (ដប់ប្រាំបីខែ)



Scanned with CamScanner

ពីបទ   បំបាត់វត្ថុតាង-បំផ្លាញចោលសារធាតុសម្រាប់ផ្សំផលិតគ្រឿងញៀន ប្រព្រឹត្តនៅចំណុចពេទ្យពុម្ពមជ្ឈមណ្ឌលអប់រំវិជ្ជាជីវៈមិត្តភាពកម្ពុជា-ជប៉ុនបឹងត្របែក សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ តាមមាត្រា ៥៣៣ នៃក្រមព្រហ្មទណ្ឌ។

ច.ឈ្មោះ [redacted]គឹមហេង ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ២៥ឆ្នាំ (ម្ភៃប្រាំឆ្នាំ) និងពិន័យជាប្រាក់ ៥០.០០០.០០០៛ (ហាសិបលានរៀល)

ពីបទ សមគំនិតក្នុងអំពើផលិតគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ និងសមគំនិតជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅចំណុចដីឡូតិ៍គ្មានលេខ ក្រុម១៤ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ តាមមាត្រា ៤៣, ៣២.១ថ្មី និងមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។

៣.វត្ថុដែលចាប់យកមានៈ

ក.ស្រោមសំបុត្រពណ៌សបិទជិត មានចុះហត្ថលេខាសមត្ថកិច្ច និងស្នាមមេដៃឈ្មោះ [redacted] អេនឌី ចំនួន ០១

.ស្រោមសំបុត្រពណ៌ស មានស្នាមមេដៃឈ្មោះ[redacted]អង់ឌី ចំនួន ០១

.កាំភ្លើងខ្លី ០១ ដើមម៉ាក PRAHA មានលេខ Z501078 បង់០១ គ្រាប់ ០៣

.សៀវភៅកំណត់អាសយដ្ឋាន និងលេខទូរស័ព្ទចំនួន ០១ក្បាល

.សៀវភៅ និងក្រដាសកំណត់ត្រាអំពីការចំណាយចំនួន ០១ច្បាប់

.កាតនាមប័ណ្ណមួយចំនួន

.កាមេរ៉ាសុវត្ថិភាព ចំនួន ១១ គ្រឿង

.កាមេរ៉ាសុវត្ថិភាព ០៣ គ្រឿង

.ក្បាលម៉ាស៊ីនថតកាមេរ៉ាម៉ាក AVT 771B ពណ៌ខ្មៅចំនួន ០១គ្រឿង

.ក្បាលចាក់កាមេរ៉ាម៉ាកAVT808G.264 DVR មួយគ្រឿងតេឡេម៉ាកDVR DVS

.សោ ALARM ម៉ាក Kinbar ចំនួន ០២

.រូបថតចំនួន ០១ អាល់ប៊ុម ពណ៌ក្រហម មានសៀវភៅដាក់រូបថតពណ៌ស ចំនួន ០១

.រថយន្តម៉ាក MISUBISHI ពាក់ស្លាកលេខ រដ្ឋ ១៦-២.០០១៣ (រថយន្តចាស់)



Scanned with CamScanner

មានដូចក្នុងកំណត់ហេតុទទួលវត្ថុតាមលេខ ២៥៩ វ.ត ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

.រថយន្តប្រភេទ ហ៊ីយនដាយ ស្លាកលេខ ២០-២៣៨១ ភ.ព (ប្រភេទខ្ទុបដឹកទឹកកក) + បំពង់ជ័រគ្រឿងញៀនដែលប្រើរួច ចំនួន ០៣

.ឡចំហុយសារធាតុញៀន ចំនួន ០១

.ធុងជ័រជាឧបករណ៍បំរើការផលិតគ្រឿងញៀន

.ម៉ូទ័រ ភ្ជាប់នឹងទុយោជ័រធំ សម្រាប់ផលិតគ្រឿងញៀន

.ធុងជ័រពណ៌ស ចំនួន ០១ + កែវចំហុយ ០១

.អំពូលភ្លើងបញ្ឈរ ចំនួន ០១ + សំបកជបប្រើប្រាស់រួច ០៤ កេស

.ធុងហ្គាស ប្រភេទ ១០ គីឡូក្រាម ចំនួន ០១

.កាធុនដែកចំនួន ០១ + លិខិតកំណត់ត្រាផលិតថ្នាំញៀនប្រចាំថ្ងៃ ០១

.ម្យៅស៊ូតសម្រាប់បន្សាប់អាស៊ីតចំនួនកន្ទះប៉ាវ

.ក្រដាសសម្រាប់ច្រោះគ្រឿងញៀន ហើយមានភ្ជាប់ថ្នាំញៀន ០៦ គីឡូក្រាម ប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកក) ក្លាយជាគ្រឿងញៀន

មានដូចក្នុងកំណត់ហេតុឆែកឆេរផ្ទះរបស់ឈ្មោះ[redacted]អនឌី ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ របស់នាយកដ្ឋានសន្តិសុខផ្ទៃក្នុង

.កេសក្រដាសដែលមានថតដាក់សារធាតុផ្សំគ្រឿងញៀន ចំនួន ១៤៥ កេស

.ធុងទឹកកកជ័រពណ៌ក្រហមចំនួន ១៥ធុង

.ម៉ូទ័រ ចំនួន ០៨, ដីឡៅកែវ ចំនួន ០៨កែវ, ចានដែក ចំនួន ១២, ធុងដែក ចំនួន ០២

.ទូរស័ព្ទចិន ពណ៌ស (ចាស់) ០១ គ្រឿង

មានដូចក្នុងកំណត់ហេតុឆែកឆេរផ្ទះរបស់ឈ្មោះហុង រស្មី ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ របស់នាយកដ្ឋានសន្តិសុខផ្ទៃក្នុង។

.រថយន្តម៉ាក LEXUS 470 ពណ៌ខ្មៅពាក់ស្លាកលេខ ភ្នំពេញ 2D 8216 គ្មានស្លាកលេខក្រោយ

.រថយន្តម៉ាក LEXUS 470 ពណ៌ខ្មៅពាក់ស្លាកលេខ ភ្នំពេញ 2D 8216 គ្មានស្លាកលេខក្រោយ



Scanned with CamScanner

.រថយន្តម៉ាក LEXUS RX 300 ពណ៌ខ្មៅពាក់ស្លាកលេខ ភ្នំពេញ 2M 9775

.រថយន្តម៉ាក STAREX ពណ៌កណ្តុរប្រផេះ ពាក់ស្លាកលេខ 2D 3810

.រថយន្តម៉ាក MISUBISHI ពណ៌លឿង ប្រភេទទីកូ មានស្លាកលេខ ភ្នំពេញ 2F 1236 មួយគ្រឿង

.ប័ណ្ណសម្គាល់យានយន្តស្លាកលេខ ភ្នំពេញ 2M 3810 ស្លាកលេខ 2M 9775 ស្លាកលេខ 2D 8216 និងស្លាកលេខ ភ្នំពេញ 2Q 2318

.ទូរដែកម៉ាក HANMI មួយមានកំពស់ ៥៥ មីលីម៉ែត្រ និងទទឹង ៥០ មីលីម៉ែត្រ

.ស្លាកលេខឡានភ្នំពេញ 2D 8216 ចំនួន ០១ សន្លឹក

.កុងតាក់ចុចប៊ូតុងក្រហម និងខៀវ ចំនួន ០១ គ្រឿង

មានដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ២៥៩ វ.ត ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

.ឯកសារមួយចំនួន

មានដូចក្នុងកំណត់ហេតុឆែកឆេរផ្ទះរបស់ឈ្មោ[redacted] សេងឡុង ហៅ[redacted]ហាន់ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៧ របស់នាយកដ្ឋានសន្តិសុខផ្ទៃក្នុង

.ផ្ទះគ្មានលេខ ដីឡូតិ៍ ក្រុម១៤ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ, ផ្ទះគ្មានលេខ ផ្លូវ៣៦៩ ភូមិព្រែកថ្មី សង្កាត់ព្រែកថ្មី ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងផ្ទះគ្មានលេខ ផ្លូវ ១២ BT ក្រុម ៥ ភូមិសន្សំកុសល៤ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

សម្រេចរឹបអូស តាមមាត្រា ៦២, ៦៣ នៃក្រមព្រហ្មទណ្ឌ។

ខ.ម៉ូតូម៉ាកហុងដាអាយខុន ពណ៌ត្នោតចេក ពាក់ស្លាកលេខ ភ្នំពេញ 1AM 0972

.ក្បាល DV៣ ម៉ាក PPCTV Digital Terrestrial Receiver ពណ៌ខ្មៅ ០១គ្រឿង

.ក្បាល DVD ម៉ាក AKIRA ពណ៌ខ្មៅ ០១គ្រឿង

.LCD ម៉ាក SAMSUNG ពណ៌ខ្មៅទំហំ ២៦ អ៊ីញ ចំនួន ០១គ្រឿង

.LCD ម៉ាក LG ពណ៌ខ្មៅទំហំ ៣២ អ៊ីញ ចំនួន ០១គ្រឿង

.ម៉ាស៊ីនព្រីន ម៉ាក EPSON មួយគ្រឿង

.ក្បាលចាក់ DVD ម៉ាកសូនី ពណ៌ខ្មៅ មួយគ្រឿង

.CPU ម៉ាក POWER CASE ពណ៌ខ្មៅ មួយគ្រឿង

.4CH Digital Video Recordor A VT 771B ពណ៌ខ្មៅ មួយគ្រឿង



Scanned with CamScanner

.Digital Camara ម៉ាកសូនី 450X ពណ៌ខ្មៅលាយទឹកប្រាក់ ០១គ្រឿង និងកាសែតម៉ាកសូនី MIP 120 ចំនួន ០១

.ប័ណ្ណសម្គាល់រថយន្តម៉ាក MISUBISHI MONTERO ស្លាកលេខ ភ្នំពេញ 2B 1117 ពណ៌ខ្មៅ ជាកម្មសិទ្ធិរបស់ឈ្មោ[redacted]សុវណ្ណ

.ស៊ីមកាតចំនួន ០២ ប្រព័ន្ធ Metfone ចំនួន ០១ មានលេខកូដ ៨៩៨៥៥០៨០១០០៣៣២៥២០៩២ និងប្រព័ន្ធ MOBETEL មានលេខកូដ ០៣០១២៨៩៩២៥

.Micro SD ទំហំ 2DB ចំនួន ០១

.បន្ទះ CD ចំនួន ០៥

.កាតអេស៊ីលីដារបស់ឈ្មោ[redacted] សុវណ្ណ ចំនួន ០១ សន្លឹក

.Laptop ម៉ាក Toshiba Model Librettoff ចំនួន ០១គ្រឿង

.វិក័យប័ត្របង់ថ្លៃអគ្គីសនីរបស់ឈ្មោះ [redacted] SAMON ស្នាក់នៅផ្ទះលេខ ០៥៥ ក្រុងតាខ្មៅ ខេត្តកណ្តាល ចំនួន ០១ច្បាប់

.ទូរស័ព្ទម៉ាក អាយម៉ូបាយ ពណ៌ប្រផេះប្រើស៊ីមពីរ មានស៊ីម ០២ មួយគ្រឿង

.ប្រាក់ដុល្លារចំនួន ១៩១ $ (មួយរយកៅសិបមួយដុល្លារអាមេរិក)

.ប្រាក់ដុល្លារចំនួន ២១ $ (សែសិបមួយដុល្លារអាមេរិក)

.អត្តសញ្ញាណប័ណ្ណខ្មែរលេខ ០២០៣២៨៣៧២ មួយសន្លឹក

.អត្តសញ្ញាណប័ណ្ណខ្មែរលេខ ០១០០៩១៧២៦ មួយសន្លឹក

.ប័ណ្ណបើកបរលេខ B.119844 មួយសន្លឹក អាយកូម ម៉ាកម៉ូតូរ៉ូឡា ០១គ្រឿង

.នាមប័ណ្ណផ្សេងៗមួយចំនួន

.ទូរស័ព្ទដៃម៉ាក សាមសុង សេរី GT-B5722 ពណ៌ខ្មៅប្រើស៊ីមពីរ មានស៊ីម ០២ មួយគ្រឿង

.ទូរស័ព្ទដៃម៉ាក សាមសុង Wave GT-S8500 ពណ៌សូកូឡា មានស៊ីម ០១ មួយគ្រឿង

.ទូរស័ព្ទដៃម៉ាក htc ពណ៌ខ្មៅ ប្រើស៊ីម ០១ មានស៊ីម ០១ មួយគ្រឿង, ប័ណ្ណបើកបរលេខ 2A.PP.00001311 មួយសន្លឹក, កាតគ្រីម៉ូតូស្លាកលេខភ្នំពេញ 1AH 7667 មួយសន្លឹក

.ទូរស័ព្ទម៉ាក NOKIA X 3 ពណ៌ទឹកប្រាក់ មានស៊ីម ០១ គ្រឿង



Scanned with CamScanner

.ទូរស័ព្ទម៉ាក NOKIA E66 ពណ៌ក្រហម គ្មានស៊ីម ០១ គ្រឿង

.ទូរស័ព្ទម៉ាកម៉ូតូរ៉ូឡា EX128 ប្រើស៊ីម ០២ ដាក់ស៊ីម ០១ មួយគ្រឿង

.ទូរស័ព្ទម៉ាក LG ពណ៌ស មានស៊ីម ០១គ្រឿង

.ទូរស័ព្ទម៉ាកណូគា E72 ពណ៌សូកូឡា មានស៊ីម ០១គ្រឿង

.ទូរស័ព្ទម៉ាកណូគា ពណ៌ខ្មៅ មានស៊ីម ០១គ្រឿង

.រថយន្តម៉ាក LEXUS GX 470 ពណ៌ខ្មៅ មានលេខតួ ៩៣០០១៩៩៧៨ ពាក់ស្លាកលេខ ភ្នំពេញ 2J 3877

.ប័ណ្ណសម្គាល់យានយន្តស្លាកលេខ ភ្នំពេញ 2J 3877

មានដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ២៤៩ វ.ត ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

.កុំព្យូទ័រមួយឈុតម៉ាក ACCER (C-V-U ម៉ូនីទ័រ, ឃី)

.លិខិតឆ្លងដែន ០២, សៀវភៅធនាគារ ០១, អេជីអ៊ីមអេស៊ីលីដា ០១ និងប័ណ្ណគ្រួសារ

.មានដូចក្នុងកំណត់ហេតុឆែកឆេរផ្ទះរបស់ឈ្មោ[redacted]ឡុង ហៅ [redacted]ហាន់ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១១ របស់នាយកដ្ឋានសន្តិសុខផ្ទៃក្នុង

.ម៉ាស៊ីនព្រីន LPSON ០១គ្រឿង, ស៊ីវីយូ ០១គ្រឿង, អំភ្លី ០១គ្រឿង

មានដូចក្នុងកំណត់ហេតុឆែកឆេរផ្ទះលេខ T ៨២ ស្ទួន ផ្លូវ ៥៣BT សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ របស់នាយកដ្ឋានសន្តិសុខផ្ទៃក្នុង

.ផ្ទះលេខ ៨២ T ស្ទួន ផ្លូវ ៥៣ BT ភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងផ្ទះលេខ ២១២ ផ្លូវលំលេខ ២៥ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

សម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ [redacted] អេនឌី , [redacted] ដារិទ្ធ, [redacted]ថាច, [redacted] គឹមហេង មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ កំបាំងមុខជនជាប់ចោទ គឹម សុវណ្ណ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១២។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។





Scanned with CamScanner

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ៩៦០ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីនី ប្ដឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៨ ក.ប.៤ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ៩៦៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] គឹមហេង ប្ដឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៨ ក.ប.៤ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ៩៩៣ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] អេនឌី ប្ដឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៨ ក.ប.៤ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី ២ "ក" និងទី៣ "ក" ។

**-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ០១ក្រVI.ភ.ស ចុះថ្ងៃទី២១ ខែមករា ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖**

១.ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៩៦០ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីនី, លេខ ៩៦៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ របស់ជនជាប់ចោទ [redacted] គឹមហេង និងលេខ ៩៩៣ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] អេនឌី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៧៨ ក.ប.៤ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

៣.បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] អេនឌី, ឈ្មោះ [redacted] គឹមហេង និងឈ្មោះ [redacted] ស្រីនី តាមនីតិវិធីច្បាប់។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] អេនឌី ឈ្មោះ [redacted] គឹមហេង និងឈ្មោះ [redacted] ស្រីនី មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] អេនឌី, ឈ្មោះ [redacted] គឹមហេង និងឈ្មោះ [redacted] ស្រីនី។

បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់។



Scanned with CamScanner

-បានឃើញ បណ្ដឹងសាទុក្ខលេខ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] គីមហេង ដែលធ្វើឡើងតាមរយៈលោក [redacted] ទ្រី និងលោក [redacted] ចេតនា ជាមេធាវីតំណាងក្នុងការប្ដឹងសាទុក្ខចំពោះសាលដីកាលេខ ០១ក្រVI.ក.ស ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ២៨ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] ស្រីនី ប្ដឹងសាទុក្ខចំពោះសាលដីកាលេខ ០១ក្រVI.ក.ស ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ២៩ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] អេនឌី ប្ដឹងសាទុក្ខចំពោះសាលដីកាលេខ ០១ក្រVI.ក.ស ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា យោងតាមឯកសារទាំងអស់នៅក្នុងសំណុំរឿងព្រហ្មទណ្ឌនេះបានបង្ហាញថាការសម្រេចសេចក្ដីរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញមានលក្ខណៈត្រឹមត្រូវហើយ ព្រោះការសម្រេចផ្អែកលើសំអាងហេតុដែលស្របតាមអង្គហេតុ និងអង្គច្បាប់ ដូចមានបញ្ជាក់នៅក្នុងខ្លឹមសារនៃសាលដីកាស្រាប់។ សមត្ថកិច្ចបានចុះចាប់ខ្លួនជនជាប់ចោទក្នុងពេលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្ដែង ហើយមន្ត្រីនគរបាលយុត្តិធម៌បានឆែកឆេរ និងរឹបអូសបានវត្ថុតាងសារធាតុគីមីផ្សំមួយចំនួន ព្រមទាំងឧបករណ៍សម្ភារៈផ្សេងៗសម្រាប់បម្រើជាមធ្យោបាយផលិតសារធាតុញៀន ដូចមានឯកសារ និងភស្តុតាងបញ្ជាក់នៅក្នុងសំណុំរឿងនេះស្រាប់។ គ្មានភស្តុតាងដោះបន្ទុកឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ទេ។ អំពើរបស់ជនជាប់ចោទគឺ បានប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ របៀបរៀបរយ សន្តិសុខសង្គម និងសុខភាពរបស់ប្រជាពលរដ្ឋយ៉ាងធ្ងន់ធ្ងរ និងបានបំពានបញ្ញត្តិច្បាប់ព្រហ្មទណ្ឌដែលបានហាមឃាត់។ កំណត់ហេតុរបស់សមត្ថកិច្ចនគរបាលយុត្តិធម៌ និងភស្តុតាងដែលប្រមូលបានទាំងអស់ បញ្ជាក់ថា ជនជាប់ចោទបានប្រព្រឹត្តបទការផលិតគ្រឿងញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ជួញដូរគ្រឿងញៀន ហាមឃាត់ខុសច្បាប់ រក្សាទុកអាវុធហាមឃាត់ខុសច្បាប់ និងការមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីផ្ដន្ទាទោសលើបទមជ្ឈិម ប្រព្រឹត្តនៅចំណុចដីឡូតិ៍គ្មានលេខ ក្រុម១៤ ភូមិស្វាយតាអុក សង្កាត់[illegible] ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមាន



Scanned with CamScanner

ចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣២.១ ថ្មី មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាត្រា ២០នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ មាត្រា ៨៧ និងមាត្រា ៩០ នៃក្រមព្រហ្មទណ្ឌ។ ហេតុដូច្នេះ យល់ឃើញថា គប្បីតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល។

-ជនជាប់ចោទឈ្មោះ [redacted] អេនឌី បានឆ្លើយថា ខ្លួនប្តឹងសាទុក្ខមកតុលាការកំពូល ដោយសារតែ សាលាឧទ្ធរណ៍បានសម្រេចផ្តន្ទាទោសខ្លួនអស់មួយជីវិត ព្រោះខ្លួនពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ទេ។ នៅថ្ងៃកើតហេតុនៅពេលសមត្ថកិច្ចធ្វើការចុះបង្ក្រាប ខ្លួនមិនបាននៅកន្លែងកើតហេតុនោះទេ ស្រាប់តែនៅពេលយប់ខ្លួនទៅដល់ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង, សមត្ថកិច្ចបានចុះបង្ក្រាបនៅទីតាំងដីឡូត៍វាលស្បូវជាកន្លែងដែលខ្លួនស្នាក់នៅ។ ការចោទប្រកាន់ទាំងអស់គឺ ពុំសុទ្ធតែជាការពិតទាំងអស់នោះទេ ខ្លួនទទួលស្គាល់ត្រឹមតែថា ខ្លួនខុសព្រោះទទួលបញ្ញើរពីមិត្តភក្រហើយយកទៅដាក់ក្នុងដីឡូត៍នោះ, សារធាតុដែលរកឃើញនោះពុំមែនជាគ្រឿងញៀនទេ វាជាទឹកអាស៊ីតដែលវាជាបញ្ញើរដែលមិត្តភក្រខ្លួនបានផ្ញើរ។ ឈ្មោះ [redacted] ស្រីនី និងខ្លួនមានទំនាក់ទំនងស្នេហាជាមួយគ្នា ហើយខ្លួនយកមកដេកមួយយប់ក៏ត្រូវសមត្ថកិច្ចចាប់ជាមួយខ្លួនតែម្តង។ ហើយឈ្មោះ [redacted] គីមហេង ជាអតីតប្អូនថ្លៃ, ខ្លួននៅតែមិនទទួលស្គាល់ថា បានផលិតគ្រឿងញៀននោះទេ, ហើយសម្រាប់អាវុធខ្លួនក៏មិនទទួលស្គាល់ដែរ ព្រោះអាវុធនោះខ្លួនគ្រាន់តែទុកដើម្បីការពារខ្លួនតែប៉ុណ្ណោះ។ កាលពីមុនខ្លួនធ្លាប់ជាប់ពន្ធនាគារពីបទ ផ្តល់ទីតាំងឱ្យគេប្រើប្រាស់គ្រឿងញៀន ហើយជាប់ពន្ធនាគារចំនួន ០១ ខែ។ ខ្លួនសំណូមពរ សុំឱ្យតុលាការកំពូលមេត្តា សម្រេចបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] គីមហេង បានឆ្លើយថា ខ្លួនប្តឹងសាទុក្ខមកតុលាការកំពូល ដោយសារតែ ការចោទប្រកាន់ពិតជាមានភាពអយុត្តិធម៌ណាស់ ព្រោះខ្លួនមិនដែលបានចូលរួមប្រព្រឹត្តបទល្មើសនោះទេ, ខ្លួនពុំដែលស្គាល់គ្រឿងញៀនទេ, ខ្លួនជាអតីតសាច់ថ្លៃជាមួយឈ្មោះ [redacted] អេនឌី។ ខ្លួនពុំដែលដឹងពីការរកស៊ីរបស់ឈ្មោះ [redacted] អេនឌី នោះទេ, នៅថ្ងៃកើតហេតុខ្លួនមិននៅទីតាំងកើតហេតុនោះទេ ខ្លួននៅផ្ទះម្តាយក្មេកស្រាប់តែត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង។ ឈ្មោះ [redacted] អេនឌី បានជួលខ្លួនឱ្យទៅយាមផ្ទះរបស់គាត់នៅដីឡូត៍វាលស្បូវ បានប្រហែលជា ០១ខែស្រាប់តែគាត់ផ្លាស់ប្តូរខ្លួនឱ្យទៅយាមផ្ទះនៅកោះក្របីវិញ ហើយក៏មានរឿងកើតឡើងតែម្តង។ ខ្លួនគ្រាន់តែដឹងថា នៅផ្ទះកើតហេតុមានបន្ទប់ ០១ សម្រាប់ខ្លួនដេក ហើយឃើញរបស់របរជាច្រើន ប៉ុន្តែខ្លួនមិនដឹងថាជាអ្វីខ្លះនោះទេ, ខ្លួនយាមផ្ទះតែពេលយប់ទេ ពេលថ្ងៃខ្លួនមកថតរូប។ ខ្លួនពុំដែលមានគំនិតថាផលិតអ្វីជាមួយ [redacted] អេនឌី ទេ ខ្លួនគ្រាន់តែ



Scanned with CamScanner

យាមផ្ទះឱ្យគាត់ប៉ុណ្ណោះ, ខ្លួនពុំដែលប្រើប្រាស់គ្រឿងញៀនទេ។ ខ្លួនសំណូមពរ សុំឱ្យតុលាការកំពូលមេត្តា រកយុត្តិធម៌ដល់ខ្លួនផងព្រោះខ្លួនត្រូវផ្តន្ទាទោស ២៤ឆ្នាំ យ៉ាងអយុត្តិធម៌បំផុត។

-ជនជាប់ចោទឈ្មោះ [redacted] ប៊ីនី បានឆ្លើយថា ខ្លួនប្តឹងមកតុលាការកំពូលដោយសារតែ គេចោទប្រកាន់មកលើខ្លួនពីបទសមគំនិត, ខ្លួនស្គាល់ឈ្មោះ [redacted] អេនឌី ដោយសារតែខ្លួនបានដើរលេងនៅខារ៉ាអូខេ ហើយត្រូវបានឈ្មោះ [redacted] អេនឌី ហៅទៅជាមួយនៅឯផ្ទះដីឡូតិ៍កៀនស្វាយ។ ខ្លួនធ្លាប់ទៅកន្លែងនោះបានប្រហែល ២ ទៅ ៣ដងហើយ។ នៅពេលខ្លួនទៅម្តងៗ ពុំដែលបានឃើញអ្វីទេគឺ គ្រាន់តែចូលក្នុងបន្ទប់គេងជាមួយឈ្មោះ [redacted] អេនឌី តែប៉ុណ្ណោះ ព្រោះបន្ទប់ផ្សេងទៀតចាក់សោរគ្រប់ទាំងអស់។ ខ្លួនពុំដែលប្រើប្រាស់គ្រឿងញៀនទេ ហើយឈ្មោ[redacted]អេនឌី ក៏ពុំដែលឱ្យគ្រឿងញៀនខ្លួនប្រើដែរ, ខ្លួនសំណូមពរសុំឱ្យតុលាការកំពូលមេត្តា សម្រេចឱ្យខ្លួនរួចផុតពីបទចោទប្រកាន់ ពីព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

-លោកស្រី [redacted] សុវ៉ែន មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted]អេនឌី និងជនជាប់ចោទឈ្មោ[redacted]ស្រីនី បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនឈ្មោះ [redacted] អេនឌី បានឆ្លើយបញ្ជាក់គ្រប់ដំណាក់កាលហើយថា មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ, គាត់ស្គាល់មិត្តភ័ក្រជាជនជាតិវៀតណាម ហើយបានយករបស់របរទៅផ្ញើរនៅនឹងគាត់ ដោយពុំដឹងថារបស់នោះជាអ្វីនោះទេ។ កូនក្តីខ្លួនទទួលស្គាល់ដែលថា របស់នោះជារបស់បញ្ញើរ តែតុលាការមកចោទប្រកាន់ថាជារបស់គាត់នោះ គឺសុំបដិសេធចោលទាំងស្រុង, ចំពោះអាវុធនោះកូនក្តីខ្លួនគ្រាន់តែយកមកប្រើប្រាស់ ដើម្បីការពារខ្លួនតែប៉ុណ្ណោះ ហើយមានលិខិតកាន់កាប់អាវុធដោយស្របច្បាប់ដែរ, របស់បញ្ញើរដែលទទួលផ្ញើរនោះវាជាជាតុផ្សំនៃសារធាតុញៀន ដូច្នេះ ក្រុមប្រឹក្សាពិចារណាទៅលើអំពើរបស់កូនក្តីខ្លួនឈ្មោះ[redacted] អេនឌី ដែលគាត់គ្រាន់តែទទួលបញ្ញើរពីគេ, សុំតុលាការកំពូលមេត្តា បន្ធូរបន្ថយទោសឱ្យជនជាប់ចោទឈ្មោះ[redacted] អេនឌី។ ចំណែកឯកូនក្តីខ្លួនឈ្មោះ [redacted] ស្រីនី គឺពុំមានការពាក់ព័ន្ធអ្វីជាមួយឈ្មោ[redacted] អេនឌីទេ, ជនជាប់ចោទឈ្មោះ[redacted] ស្រីនី គឺគ្រាន់តែជាស្រីបម្រើផ្លូវភេទតែប៉ុណ្ណោះ នៅថ្ងៃកើតហេតុនៅពេលដែលឈ្មោះ[redacted]ស្រីនី មកគេជាមួយនឹងឈ្មោ[redacted]អេនឌី ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនជាមួយតែម្តង។ កូនក្តីខ្លួនឈ្មោ[redacted]ស្រីនី ពុំដែលបានទទួលកម្រៃអ្វីពីអំពើប្រព្រឹត្តរបស់ឈ្មោះ [redacted]អេនឌី នោះទេ, សាលាដំបូងពុំបានស៊ើបអង្កេតឱ្យបានច្បាស់លាស់ទេ បែរជាសម្រេចឱ្យឈ្មោះ[redacted] ស្រីនី ជាប់ពន្ធនាគារយ៉ាងអយុត្តិធម៌ទៅវិញ។ នៅក្នុងអង្គហេតុ



Scanned with CamScanner

មានវិមតិសង្ស័យនៅឡើយ ដូច្នេះ ខ្ញុំសំណូមពរ សុំឱ្យតុលាការកំពូលមេត្តាពិចារណាទៅលើចំណុចនៃអង្គហេតុរបស់ឈ្មោះ [redacted] ស្រីនី និងសម្រេចឱ្យឈ្មោះ [redacted] ស្រីនី រួចផុតពីបទចោទប្រកាន់។

-លោក [redacted]ចតនា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] គឹមហេង បានធ្វើសេចក្តីសន្និដ្ឋានថា សាលាឧទ្ធរណ៍ពុំបានផ្តល់យុត្តិធម៌ដល់កូនក្តីខ្ញុំទេ។ កូនក្តីខ្ញុំបានបដិសេធគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការហើយថា មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ, កូនក្តីខ្ញុំគ្រាន់តែជាអ្នកយាមផ្ទះឱ្យឈ្មោះ[redacted]អេនឌី តែប៉ុណ្ណោះ មិនបានដឹងថា [redacted] អេនឌី ធ្វើអ្វី ឬរកស៊ីអ្វីនោះទេ។ កូនក្តីខ្ញុំគ្មានចេតនាក្នុងការប្រព្រឹត្តបទល្មើសទេ, ខ្ញុំសំណូមពរ សុំឱ្យតុលាការកំពូល សម្រេចឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទប្រកាន់។

-លោក [redacted] គឹមហ៊ត់ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]គឹមហេង បានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ[redacted]អេនឌី បានឆ្លើយហើយថា កូនក្តីខ្ញុំគ្រាន់តែជាអតីតសាច់ថ្លៃ ហើយហៅមកឱ្យយាមផ្ទះតែប៉ុណ្ណោះ។ ហើយកូនក្តីខ្ញុំបានឆ្លើយហើយថា យាមផ្ទះឱ្យឈ្មោះ[redacted] អេនឌី តែពេលយប់, ហើយពុំបានដឹងថាមានអ្វីនៅក្នុងផ្ទះនោះទេ, ឈ្មោះ[redacted] អេនឌី បានឱ្យបន្ទប់ ០១ សម្រាប់កូនក្តីខ្ញុំស្នាក់នៅពេលយប់តែប៉ុណ្ណោះ ហើយបន្ទប់ផ្សេងគឺចាក់សោរទាំងអស់។ កូនក្តីខ្ញុំយាមផ្ទះឱ្យឈ្មោះ[redacted] អេនឌី បាន ០១ខែ ក៏ត្រូវឈ្មោះ [redacted]អេនឌី ផ្លាស់ប្តូរកូនក្តីខ្ញុំពីផ្ទះនៅវាលស្បូវ ទៅយាមនៅផ្ទះនៅឯកោះក្របីវិញ, ការចោទប្រកាន់កូនក្តីខ្ញុំពីបទ សមគំនិតនោះគឺ ពុំត្រឹមត្រូវទេ នៅថ្ងៃកើតហេតុកូនក្តីខ្ញុំពុំបាននៅកន្លែងកើតហេតុទេ, កន្លែងកើតហេតុគឺនៅឯវាលស្បូវ តែកូនក្តីខ្ញុំបានយាមនៅឯកោះក្របីឯណោះទេ។ កូនក្តីខ្ញុំគ្មានចេតនាណាមួយ ជួយសម្រួលដល់ជនជាប់ចោទឈ្មោះ [redacted]អេនឌី ក្នុងការប្រព្រឹត្តបទ ផលិតគ្រឿងញៀននោះទេ គឺគ្រាន់តែជាអ្នកយាមផ្ទះឱ្យគេតែប៉ុណ្ណោះ។ ខ្ញុំសំណូមពរ សុំឱ្យតុលាការកំពូល សម្រេចឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទ។

-លោក [redacted]ខង មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]គឹមហេង បានធ្វើសេចក្តីសន្និដ្ឋានថា ខ្ញុំសុំឯកភាពតាមសហការីរបស់ខ្ញុំទាំងស្រុង។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## តុលាការកំពូល

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់លោកមេធាវី [redacted]ទ្ធី និងលោក [redacted] ចេតនា ការពារសិទ្ធិឱ្យឈ្មោះ [redacted]មហេង, បណ្តឹងសាទុក្ខលេខ ២៨ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីនី និងបណ្តឹងសាទុក្ខលេខ ២៩ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] អេនឌី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.យល់ឃើញថា ការដែលបុគ្គលប្តឹងសាទុក្ខជនជាប់ចោទឈ្មោះ [redacted] អេនឌី បានឆ្លើយដោះសារក៏ដូចជាមេធាវីការពារសិទ្ធិរបស់ខ្លួន បានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការជេញដោលនេះថា ករណីតុលាការអង្គហេតុបានកំណត់ពិរុទ្ធភាពខ្លួនក្នុងបទល្មើសពាក់ព័ន្ធនឹងការផលិតកែច្នៃគ្រឿងញៀនដោយខុសច្បាប់, ជួញដូរគ្រឿងញៀនដោយខុសច្បាប់ និងការរក្សាទុកអាវុធដោយខុសច្បាប់ ប្រព្រឹត្តនៅស្ថិតក្នុងដីឡូតិ៍គ្មានលេខ ក្រុមទី១២ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ បទល្មើសដែលមានបញ្ញត្តិតាមមាត្រា ៣២.១ថ្មី, មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ និងមាត្រា ៨៧, មាត្រា ៩០ នៃក្រមព្រហ្មទណ្ឌ ថាជាការកំណត់ពិរុទ្ធភាពខុស ពីព្រោះការពិតឧបករណ៍ផលិតគ្រឿងញៀន និងសារធាតុគ្រឿងញៀនខុសច្បាប់ទាំងនេះ មិនមែនជារបស់ខ្លួនទេ តែជារបស់ឈ្មោះ ណាំ ជនជាតិវៀតណាម និងមិត្តម្នាក់ទៀតមិនស្គាល់ឈ្មោះ បានផ្ញើរទុកនៅទីកន្លែងកើតហេតុ គឺពួកគេជាអ្នកតំឡើងឧបករណ៍ទាំងនោះ ដែលអ្នកទាំងពីរខាងលើមិនឱ្យខ្លួនចូលមើលទេ ព្រោះខ្លាចខ្លួនលួចចំណេះរបស់ពួកគេ ហេតុនេះក្នុងអង្គហេតុនៃរឿងក្តីនេះ ខ្លួនគ្មានកំហុសព្រហ្មទណ្ឌក្នុងបទល្មើសពាក់ព័ន្ធនឹងគ្រឿងញៀនដោយខុសច្បាប់ទេនោះ។ តុលាការកំពូលពិនិត្យឃើញថា ជាការមិនត្រឹមត្រូវទេ ព្រោះថាវិធានការបង្ក្រាបស្ថិតក្នុងបទល្មើសជាក់ស្តែង ឯជនជាប់ចោទរូបនេះរួមនឹងសហជនជាប់ចោទផ្សេងទៀត ក៏ត្រូវបានចាប់ឃាត់ខ្លួននាកន្លែងកើតហេតុផ្ទាល់ ហើយតាមភស្តុតាងនានាក្នុងដំណាក់កាលអង្កេត ដូចជា ចម្លើយរបស់ជនជាប់ចោទម្នាក់ៗ រួមនឹងលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ១២០៨/១១ ម.ព.អ.ជ.ប.គ.ញ និងលេខ ១២០៩/១១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញថា ភស្តុតាងទាំងនេះមានភាពស៊ីសង្វាក់គ្នា ហើយតាមមាត្រា១១០ (អំណាចធ្វើមូលវិចារណ៍របស់



Scanned with CamScanner

ចៅក្រម) និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ថា កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ដើម ដែលត្រូវជឿរហូតដល់មានកស្តុតាងផ្ទុយ ដែលការណ៍នេះ កស្តុតាងផ្ទុយមិនទាន់ត្រូវបានបង្ហាញនៅឡើយទេ រីឯចម្លើយដោះសាររបស់ជនជាប់ចោទគ្រាន់តែជាការអនុវត្តសិទ្ធិ មិនមែនជាកស្តុតាងផ្ទុយទេ ដោយឡែក ចំពោះកាំភ្លើងម៉ាក PRAHA លេខ Z៥០១០៧៨ គឺជនជាប់ចោទបានសារភាពថា ខ្លួនទិញពីអ្នកដទៃ ដើម្បីទុកការពារខ្លួន។ ករណីនេះ កស្តុតាងដាក់បន្ទុកដែលប្រមូលបាន មានលក្ខណៈជួនល្មម និង ហួសពីវិមតិសង្ស័យកំណត់បាន នូវអត្ថិភាពនៃបទល្មើស និងពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] អេនឌី ដូចការកំណត់របស់តុលាការអង្គហេតុ ដែលមានសំអាងហេតុច្បាស់លាស់អស់ហើយ។ ដូច្នេះ ចម្លើយដោះសាររបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានការពាររបស់ជនជាប់ចោទ មិនចូលក្នុងមូលហេតុនៃបណ្តឹងសាទុក្ខ ដូចការកំណត់នៃមាត្រា ៤១៩ (មូលហេតុនៃបណ្តឹងសាទុក្ខ) នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

៣យល់ឃើញថា ការដែលបុគ្គលប្តឹងសាទុក្ខជនជាប់ចោទឈ្មោះ [redacted] គឹមហេង បានឆ្លើយដោះសារក៏ដូចជាមេធាវីការពារសិទ្ធិរបស់ខ្លួន បានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការជេញដោលនេះថា ករណីតុលាការអង្គហេតុបានកំណតពិរុទ្ធភាព ភាគីខ្លួនក្នុងបទល្មើសសមគំនិតក្នុងអំពើផលិតគ្រឿងញៀនដោយខុសច្បាប់ និងសមគំនិតជួញដូរគ្រឿងញៀនដោយខុសច្បាប់តាមមាត្រា ៤៣, មាត្រា ៣២.១ថ្មី និងមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ស្ថិតក្នុងអង្គហេតុតែមួយជាមួយនឹងអំពើល្មើសព្រហ្មទណ្ឌរបស់ជនជាប់ចោទឈ្មោះ [redacted] អេនឌី ផងដែរថា ការកំណត់ពិរុទ្ធភាពដោយមានកំហុសឆ្គង ដោយដោះសារថាខ្លួនគ្រាន់តែស៊ីឈ្នួលជួយយាមទីកន្លែងកើតហេតុដើម្បីការពារសន្តិសុខ និងការពារផលដំណាំប៉ុណ្ណោះ ហេតុនេះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ តុលាការកំពូលពិនិត្យឃើញថា ជាការមិនត្រឹមត្រូវទេ ព្រោះថា ជនជាប់ចោទឈ្មោះ [redacted] គឹមហេង ទទួលស្គាល់ថា ខ្លួនជាអ្នកយាមទីកន្លែងកើតហេតុហើយ រីឯការបង្ក្រាបស្ថិតក្នុងបទល្មើសជាក់ស្តែង ដែលវត្ថុតាងជាច្រើនសន្ធឹកសន្ធាប់ត្រូវបានចាប់យកបានពីកន្លែងកើតហេតុ ហេតុនេះផ្អែកតាមគោលការណ៍សច្ចធារណ៍នៃកស្តុតាង គឺអាចវាយតម្លៃបានថា សកម្មភាពយាមរបស់ជនជាប់ចោទ [redacted] គឹមហេង គឺជាការសម្រួលដល់សកម្មភាពល្មើសព្រហ្មទណ្ឌរបស់ចារីឈ្មោះ [redacted] អេនឌី។ ករណីនេះតាមកស្តុតាងនានាក្នុងដំណាក់កាលអង្កេត, ចម្លើយរបស់ជនជាប់ចោទផ្ទាល់ រួមនឹងលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ១២០៨/១១ ម.ព.អ.ជ.ប.គ.ញ និងលេខ ១២០៩/១១ ម.ព.អ.ជ.ប.គ.ញ



Scanned with CamScanner

ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញថាមានភាពស៊ីសង្វាក់គ្នាមានតម្លៃជាភស្តុតាងដាក់បន្ទុកជនល្មើស កំណត់បាននូវអត្ថិភាពនៃបទល្មើស និង ពិរុទ្ធភាពលើជនជាប់ចោទ[redacted]គីមហេង ដូចការកំណត់របស់តុលាការអង្គហេតុហើយ។

៤-យល់ឃើញថា ការដែលសាលាដំបូង ក៏ដូចជាសាលាឧទ្ធរណ៍ផងដែរ ដែលបាន កំណត់ពិរុទ្ធភាព និងប្រកាសផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ[redacted] ស្រីនី ដាក់ពន្ធនាគារ ចំនួន ២០ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤០លានរៀល ពីបទ ការផលិតគ្រឿងញៀនដោយខុសច្បាប់ និងជួញដូរគ្រឿងញៀនដោយខុសច្បាប់ បទល្មើសដែលមានបញ្ញត្តិតាមមាត្រា ៣២.១ ថ្មី និងមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនស្ថិតក្នុងអង្គហេតុតែមួយ ជាមួយនឹងអំពើល្មើសព្រហ្មទណ្ឌរបស់ជនជាប់ចោទឈ្មោះ [redacted] អេនឌី ផងដែរនោះ មិនទាន់មានមូលដ្ឋានសំអាងហេតុនៃភស្តុតាងដាក់បន្ទុកជនល្មើសនៅឡើយទេ ព្រោះថា ៖

ក.គ្រប់ដំណាក់កាលនៃនីតិវិធី ចម្លើយជនជាប់ចោទឈ្មោ[redacted]អេនឌី ដែលជា ចារីចំបង មិនបានឆ្លើយដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ស្រីនី ទេ គឺគ្រាន់តែឆ្លើយជាអាទិ៍ថា ពួកខ្លួនទើបនឹងស្គាល់គ្នានាខែកុម្ភៈ ឆ្នាំ២០១១ មុនកើតហេតុតែប៉ុន្មានថ្ងៃប៉ុណ្ណោះ, ការទំនាក់ទំនងគ្នាក្នុងលក្ខណៈជានារីកំណាន់, ឈ្មោះ [redacted] ស្រីនី មិនពាក់ព័ន្ធនឹងរឿងគ្រឿងញៀនទាំងនេះ ហើយនាថ្ងៃកើតហេតុដែលសមត្ថកិច្ចខ្លួនឃាត់ខ្លួននោះ គឺគ្រាន់តែភាពចៃដន្យដែលឈ្មោះ[redacted] ស្រីនី ត្រូវមកដេកជាមួយខ្លួន ហើយយប់ជ្រៅពេក មិនអាចត្រលប់ទៅផ្ទះវិញ ក៏ដេកនៅទីកន្លែងកើតហេតុតែម្តង។

ខ.សក្ខីកម្មឈ្មោះ[redacted]វ៉ាន់ណេត ជាប្អូនប្រុសរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីនី មានខ្លឹមសារប្រហាក់ប្រហែលទៅនឹងចម្លើយជនជាប់ចោទឈ្មោះ [redacted] អេនឌី ដែលថាខ្លួន (ឈ្មោះ [redacted]ន់ណេត) គ្រាន់តែឌុបបងស្រីឈ្មោះ [redacted] ស្រីនី ទៅកន្លែងកើតហេតុ ៣ដង ហើយនៅលើកទីបី គឺបានដេកនៅទីនោះ ក៏ត្រូវបានសមត្ថកិច្ចចុះប្រតិបត្តិការចាប់ ឃាត់ខ្លួនជាមួយអ្នកដទៃទៀតតែម្តង។

ហើយលើសពីនេះទៀតសក្ខីកម្មឈ្មោះ [redacted] វ៉ាន់ណេត ក៏មានលក្ខណៈប្រហាក់ប្រហែលទៅនឹងចម្លើយជនជាប់ចោទឈ្មោះ[redacted] ស្រីនី ទាំងនៅចំពោះមុខនគរបាលយុត្តិធម៌ និងដំណាក់កាលនីតិវិធីបន្តបន្ទាប់មកទៀត គឺថាខ្លួន (ជនជាប់ចោទឈ្មោះ[redacted] (ស្រីនី) ទើបនឹងស្គាល់ជនជាប់ចោទឈ្មោះ [redacted] អេនឌី ដែលជាចារីចំបង មុនកើតហេតុតែប៉ុន្មានថ្ងៃ ហើយធ្លាប់ទៅកន្លែងកើតហេតុចំនួនបីដង ដែលបើកទី៣ មិនបានមកផ្ទះវិញទេ ដោយសារយប់ជ្រៅ



Scanned with CamScanner

ពេក ក៏ដេកនៅទីនោះៗ បន្ទាប់មក ក៏ត្រូវសមត្ថកិច្ចចុះប្រតិបត្តិការចាប់ខ្លួន ឃាត់ខ្លួន រហូតដល់សព្វថ្ងៃៗ ខ្លួនមិនជាប់ពាក់ព័ន្ធនឹងរឿងគ្រឿងញៀនជាមួយជនជាប់ចោទឈ្មោះ [redacted] អេនឌី ទេ គឺខ្លួនមានទំនាក់ទំនងជាអ្នករកស៊ីផ្លូវភេទប៉ុណ្ណោះៗ

គ.សក្ខីកម្មឈ្មោះ [redacted] ភារិទ្ធ ជាសមត្ថកិច្ចនគរបាលយុត្តិធម៌ នៅចំពោះមុខសវនាការជាសាធារណៈនៃសាលាដំបូង មានខ្លឹមសារថា នាយប់កើតហេតុ សមត្ថកិច្ចឃាត់ខ្លួនមនុស្សបីនាក់ ដោយឈ្មោះ [redacted] អេនឌី ឃាត់ជាក់ស្តែងកំពុងតែជក់ស្ងួថ្នាំញៀន ចំណែកឯឈ្មោះ [redacted] ស្រីនី និងឈ្មោ[redacted]វ៉ាន់ណេត នៅក្នុងបន្ទប់ផ្សេងៗ

ឃ.នៅចំពោះមុខនគរបាលយុត្តិធម៌ ជនជាប់ចោទឈ្មោះ [redacted] ស្រីនី និងប្អូនប្រុសឈ្មោះ [redacted] វ៉ាន់ណេត បានឆ្លើយតបទៅនឹងសំណួរទីមួយរបស់សមត្ថកិច្ចថា "...បានជាសមត្ថកិច្ចនាំខ្លួន មកកាន់ការិយាល័យប្រឆាំងគ្រឿងញៀន ពីព្រោះ ខ្លួនសមគំនិត ក្នុងការផលិតគ្រឿងញៀន..." ក៏ប៉ុន្តែឆ្លើយតបទៅនឹងសំណួរបន្តបន្ទាប់មកទៀត ឃើញថា គ្មានខ្លឹមសារពាក់ព័ន្ធអំពើសមគំនិត ដូចមានកំណត់តាមមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌឡើយៗ ចម្លើយជាបន្តបន្ទាប់ គ្រាន់តែបង្ហាញអំពីទំនាក់ទំនងជាទូទៅ រហូតដល់ថ្ងៃចាប់ខ្លួនអ្នកទាំងពីរ ដូចមានក្នុងខ្លឹមសារខាងលើនេះស្រាប់ៗ ហើយលើសពីនេះទៀត ចំពោះ មុខអាជ្ញាធរតុលាការ ជនជាប់ចោទ ក៏ដូចជាឈ្មោះ [redacted] វ៉ាន់ណេត បានបដិសេធ នូវផ្នែកនៃចម្លើយដែលមានខ្លឹមសារថា ជាការសមគំនិតដែរៗ បើពិនិត្យលើកំណត់ហេតុនៃការចាប់យកវត្ថុតាង និងទទួលស្គាល់វត្ថុតាង នៅមុខនគរបាលយុត្តិធម៌មានតែស្នាមម្រាមដៃឈ្មោ[redacted] អេនឌី ប៉ុន្តែគ្មានស្នាមម្រាមដៃជនជាប់ចោទឈ្មោះ [redacted] ស្រីនី ទេៗ ករណីនេះ សំណួរ ចម្លើយដំបូងថា "...ផ្សំគំនិត..." រួមនឹងសំណួរ ចម្លើយបន្តបន្ទាប់នៃកំណត់ហេតុដដែល របស់អ្នកពីរ គ្រាន់តែជាការយល់ឃើញជាទូទៅ របស់សាមញ្ញជន ដែលត្រូវបានចាប់ខ្លួន ភ្ជាមជាមួយនឹងជនជាប់ចោទផ្សេងទៀត ដែលមិនមែនជាសញ្ញាណ រួមផ្សំតាមផ្លូវច្បាប់កំណត់ដោយមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌឡើយ ។

តាមរយៈភស្តុតាងទាំងនេះ ជាពិសេសសក្ខីកម្មឈ្មោះ [redacted] ភារិទ្ធ ជានគរបាលយុត្តិធម៌ពិបាកនឹងសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] ស្រីនី មានការពាក់ព័ន្ធក្នុងអង្គហេតុនៃការរកស៊ីគ្រឿងញៀនជាមួយជនជាប់ចោទឈ្មោះ [redacted] អេនឌី ។ ដូច្នេះ គប្បីតុលាការអង្គហេតុពិនិត្យ និងវាយតម្លៃអំពីភស្តុតាងទាំងនេះជាថ្មីៗ

៩-យល់ឃើញថា តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល បានសន្និដ្ឋានប្តឹងសុំ នៅក្នុងកិច្ចពិភាក្សាដេញដោលនាពេលសវនាការថា រឿងក្តីនេះមាន



Scanned with CamScanner

ភស្តុតាងដាក់បន្ទុកជនល្មម ដូចមានក្នុងសំអាងហេតុច្បាស់លាស់ត្រឹមត្រូវ របស់សាលាឧទ្ធរណ៍ ហេតុនេះស្នើសុំតម្កល់សាលដីកាសាលាឧទ្ធរណ៍។ សេចក្តីសន្និដ្ឋាន នេះមានលក្ខណៈត្រឹមត្រូវខ្លះដែលតុលាការកំពូលបានធ្វើសំអាងហេតុ ដូចមានខាងលើ។

៦-យល់ឃើញថា តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទម្នាក់ៗ បានលើកឡើងថា ក្នុងរឿងក្តីនេះ ភស្តុតាងដាក់បន្ទុកស្ថិតក្នុងវិមតិសង្ស័យ ដែលគប្បី តុលាការអនុវត្តមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សេចក្តីសន្និដ្ឋាននេះ មានលក្ខណៈមិនត្រឹមត្រូវទាំងស្រុងនោះទេ ដែលការណ៍នេះ តុលាការកំពូលបានធ្វើសំអាងហេតុដូចខាងលើ។

៧-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ០១ ក្រV.ក.ស ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមគតិច្បាប់។

៨-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ០១ ក្រVI.ក.ស ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលសម្រេចមកនេះ ត្រឹមត្រូវខ្លះ ខុសខ្លះ។

**ហេតុដូច្នេះ**

**សម្រេច**

១-បដិសេធបណ្តឹងសាទុក្ខលេខ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់លោក [redacted]ទ្រី និងលោក[redacted]ចេតនា មេធាវីការពារសិទ្ធិទទួលសិទ្ធិឱ្យប្តឹងសាទុក្ខពីជនជាប់ចោទឈ្មោះ[redacted]គីមហេង ។

២.បដិសេធបណ្តឹងសាទុក្ខលេខ ៤៩ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted]អេងឌី ។

៣.ទទួលបណ្តឹងសាទុក្ខលេខ ៤៨ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ ជនជាប់ចោទឈ្មោះ [redacted]ស្រីនី ។

៤-តម្កល់ផ្នែកខ្លះនៃសាលដីកាព្រហ្មទណ្ឌលេខ ០១ ក្រVI.ក.ស ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ២០២១. របស់សាលាឧទ្ធរណ៍ភ្នំពេញ លើកលែងតែចំណុចដែលសម្រេចលើករណីជនជាប់ចោទឈ្មោះ [redacted] ស្រីនី ដែលត្រូវបដិសេធ។

៥-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ៥៨ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះសាជាថ្មីអំពីចំណុច ដែលត្រូវបដិសេធខាងលើនេះ។



Scanned with CamScanner

សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១។

-លោកជំទាវ [redacted] ប្រធាន

-ឯកឧត្តម [redacted] ចៅក្រម

-ឯកឧត្តម [redacted] ចៅក្រម

-ឯកឧត្តម [redacted] ចៅក្រម

-ឯកឧត្តម [redacted] ចៅក្រម

-កញ្ញា [redacted] ក្រឡាបញ្ជី

---

**បានឃើញ**

ថ្ងៃពុធ ២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ត្រូវនឹងថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ត្រូវនឹងថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner